# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៤៥/២១ ក.ប/ស.ជ.ណ.ព.ក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រារព្ធទិវាពិភពលោក ដើម្បីសុវត្ថិភាព និងសុខភាពការងារ
## ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត និយោជក សហព័ន្ធសហជីព ព្រមទាំងកម្មករនិយោជិត នៃរោងចក្រ សហគ្រាសទាំងអស់ ឱ្យបានជ្រាបថា **ទិវាពិភពលោកដើម្បីសុវត្ថិភាព និងសុខភាពការងារ** ត្រូវបានរៀបចំឡើង នៅថ្ងៃទី២៨ ខែមេសា ជារៀងរាល់ឆ្នាំ ដោយប្រទេសជាសមាជិកនៃអង្គការអន្តរជាតិខាងការងារ ក្នុងគោលបំណង ដើម្បីលើកកម្ពស់សុវត្ថិភាព និងសុខភាពការងារ និងរំលឹកដល់វិញ្ញាណក្ខន្ធកម្មករនិយោជិត ដែលបានបាត់បង់ជីវិតដោយសារគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈនៅលើពិភពលោក។ នេះជាឆ្នាំទី១៦ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រារព្ធទិវាពិភពលោកដើម្បីសុវត្ថិភាព និងសុខភាពការងារ ក្រោមប្រធានបទ «**ត្រៀមទុកជាមុន រៀបចំ ឆ្លើយតបទៅនឹងវិបត្តិ៖ ស្តារឡើងវិញនូវប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ ប្រកបដោយប្រសិទ្ធភាព**»។

ដើម្បីរួមចំណែកក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់សុវត្ថិភាព និងសុខភាពការងារ និងបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ ជាយថាហេតុដល់បងប្អូនកម្មករនិយោជិត សូមលោក លោកស្រីប្រធាន ឬម្ចាស់រោងចក្រ សហគ្រាសទាំងអស់ ដែលបានបោះទីតាំងនៅតាមបណ្តារាជធានី-ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំចងបដាពាក្យស្លោកមួយចំនួននៅតាមរបងខាងមុខរោងចក្រ សហគ្រាស ដើម្បីចូលរួមអបអរសាទរទិវាពិភពលោក ដើម្បីសុវត្ថិភាព និងសុខភាពការងារ មានដូចខាងក្រោម៖

១. អបអរសាទរទិវាពិភពលោកដើម្បីសុវត្ថិភាព និងសុខភាពការងារ
២. ត្រៀមទុកជាមុន រៀបចំ ឆ្លើយតបទៅនឹងវិបត្តិ៖ ស្តារឡើងវិញនូវប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ ប្រកបដោយប្រសិទ្ធភាព
៣. សុវត្ថិភាព និងសុខភាព និងអនាគតនៃការងារ
៤. បង្កើនសុក្រឹត្យភាពក្នុងការប្រមូល និងប្រើប្រាស់ទិន្នន័យសុវត្ថិភាព និងសុខភាពការងារ
៥. ត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារនៅគ្រប់កន្លែងធ្វើការ
៦. សុវត្ថិភាពការងារ ជាអាទិភាពទីមួយរបស់យើង
៧. រួមគ្នាកសាងវប្បធម៌ នៃការបង្ការសុវត្ថិភាព និងសុខភាពការងារ
៨. រួមគ្នាការពារសិទ្ធិការងារ និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសការងារប្រកបដោយសុវត្ថិភាព
៩. យើងរួមគ្នាតត្រាទុក និងជូនដំណឹងអំពីគ្រោះថ្នាក់ ជំងឺវិជ្ជាជីវៈ និងការកើតឡើងដោយគ្រោះថ្នាក់
១០. ចូរប្រើប្រាស់ទិន្នន័យអំពីគ្រោះថ្នាក់ និងជំងឺវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៨ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

១១.យើងរួមគ្នាជំរុញឱ្យមានប្រព័ន្ធថ្នាក់ជាតិសម្រាប់រាយការណ៍ ការប្រមូលទិន្នន័យ និងការវិភាគអំពីគ្រោះថ្នាក់ និងជំងឺវិជ្ជាជីវៈ

១២.មានសុវត្ថិភាពការងារ គឺគ្មានគ្រោះថ្នាក់ការងារ

១៣.ភាពតានតឹងអារម្មណ៍នៅកន្លែងធ្វើការជាក្តីកង្វល់របស់យើងទាំងអស់គ្នា

១៤.ធានាឱ្យគ្រប់កន្លែងការងារមានសុវត្ថិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា

១៥.កន្លែងការងារប្រកបដោយសុវត្ថិភាព និងសុខភាពល្អ នាំឱ្យកើនផលិតភាព និងប្រាក់ចំណូល

១៦.គន្លឹះឈានទៅរកសុវត្ថិភាពការងារ គឺស្ថិតនៅក្នុងដៃលោកអ្នក

១៧.វិធានសុវត្ថិភាពការងារជាមធ្យោបាយប្រសើរបំផុតនៅកន្លែងធ្វើការ

១៨.និយោជកត្រូវផ្តល់សម្ភារការពារបុគ្គលដល់កម្មករនិយោជិត

១៩. រួមគ្នាកាត់បន្ថយគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ

២០.ការឈឺចាប់កើតចេញពីកន្លែងធ្វើការងារដែលគ្មានសុវត្ថិភាព

២១.ជីវិតរបស់ខ្ញុំ ការងាររបស់ខ្ញុំ និងការងារប្រកបដោយសុវត្ថិភាពរបស់ខ្ញុំ

២២.ការងារសមរម្យ គឺជាការងារប្រកបដោយសុវត្ថិភាព

២៣.សុវត្ថិភាពការងារជាជម្រើសដែលអ្នកត្រូវជ្រើសរើសជាចាំបាច់

២៤.រួមគ្នាការពារហានិភ័យដែលកើតឡើងដោយភាពតានតឹងអារម្មណ៍នៅកន្លែងធ្វើការ

២៥.បង្ការ និងទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ និងលប់បំបាត់ការរើសអើងនៅកន្លែងការងារ

២៦.គ្រឿងញៀនបំផ្លាញសុខភាព និងអនាគតរបស់យើង

២៧.ចូរតាមមើលជាប្រចាំអំពីវិធានការណ៍បង្ការនានា ដើម្បីកុំឱ្យមានបាតុភូតមហន្តរាយនៅកន្លែងការងារ

២៨.គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ មានផលប៉ះពាល់ដល់ជីវិតរស់នៅជាប្រចាំរបស់កម្មករនិយោជិត និងគ្រួសាររបស់ពួកគេ

២៩.រួមគ្នាពង្រឹងគណៈកម្មការសុវត្ថិភាព និងសុខភាពការងារ តាមរយៈបង្កើនការយល់ដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន

៣០.លើកស្ទួយការយល់ដឹងអំពីសុវត្ថិភាព និងសុខភាពការងារដល់កម្មករនិយោជិត និងគណៈកម្មការសុវត្ថិភាព និងសុខភាពការងារ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត សមាគមនិយោជក និងនិយោជក ព្រមទាំងសហព័ន្ធសហជីពនៃរោងចក្រ សហគ្រាសទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។ ៤៩

ថ្ងៃ ព្រហស្បតិ៍ ៨កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ពស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
- សមាគមនិយោជក
- សហព័ន្ធសហជីព
- ឯកសារ-កាលប្បវត្តិ